# JICA Cambodia Office - JICA カンボジア事務所

May 3 at 12:07 PM ·

[សិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំថ្នាក់ជាតិស្តីពី ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក នៃគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (The Strings)/ Dissemination Workshop of the National Guideline on In-Service Training for Nurses (INSET) of the Project for Strengthening of In-Service Training System in Cambodia (The Strings)]

------------------------------

នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ក្រសួងសុខាភិបាល និងគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (Strings) របស់ JICA បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនសុជាតិ អនុរដ្ឋលេខាធិការនៃក្រសួងសុខាភិបាល និងតំណាងសំខាន់ៗមកពីក្រសួងសុខាភិបាល គណៈគិលានុបដ្ឋាកកម្ពុជា (CCN) មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងមន្ទីរពេទ្យបង្អែកខេត្ត កំពង់ស្ពឺ តាកែវ កំពត ព្រះសីហនុ និងកោះកុង (ក្រុមខេត្តដំបូងសម្រាប់ការផ្សព្វផ្សាយនេះ) សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពត និងអង្គការ GIZ, FHI360។

ជាកិច្ចចាប់ផ្តើមនៃសិក្ខាសាលា គឺមានការបង្ហាញពីដំណើរការនៃការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ និងទិដ្ឋភាពទូទៅ ក្រោយមកគឺមានពិធីប្រគល់សៀវភៅគោលការណ៍ណែនាំថ្នាក់ជាតិ ជូនសិក្ខាកាមជានិមិត្តរូបចំនួន ៥ រូប តំណាងឲ្យសិក្ខាកាមទាំងអស់ និងមានបទបង្ហាញពន្យល់នូវក្របខ័ណ្ឌបណ្តុះបណ្តាលក្នុងសេចក្តីណែនាំថ្នាក់ជាតិផងដែរ។

បញ្ហាប្រឈមជាក់ស្តែងក្នុងការដឹកនាំវគ្គបណ្តុះបណ្តាលនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) ដោយប្រើប្រាស់គោលការណ៍ណែនាំត្រូវបានពិភាក្សាយ៉ាងសកម្ម ដូចជាការគ្រប់គ្រងធនធាន លក្ខណៈវិនិច្ឆ័យនៃការផ្តល់វិញ្ញាបនបត្រ និងប្រព័ន្ធគ្រប់គ្រងរបាយការណ៍។

គម្រោងនឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយបន្ថែមសម្រាប់បណ្តាខេត្តក្រុងដទៃផ្សេងទៀតនាពេលខាងមុខអំពីគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាកនេះ៕

អត្ថបទ៖ Strings Project

On 28th April 2023, the Ministry of Health (MoH) with the Strings project successfully co-organized the Dissemination Workshop of the National Guideline on In-Service Training for Nurses (INSET) at the Sokha Phnom Penh Hotel presided over by H.E. Prof. Mam Bunsocheat, Under Secretary of State and also key representatives from MoH, Cambodian Council of Nurses (CCN), national hospitals, national centers, provincial administration health departments, provincial hospitals, regional training centers in Kampong Speu, Takeo, Kampot, Preah Sihanouk and Koh Kong (the first provincial group for dissemination), and international donors (GIZ and FHI360).

At the beginning of the Dissemination Workshop, the process of developing INSET guideline and its overview were introduced. After the official handover of the guideline to 5 representatives as a symbol, and the training framework in the guideline was mainly explained.

The actual challenges to conduct the training as a part of Continuing Professional Development (CPD) by utilizing the guideline were enthusiastically discussed, such as resource management, criteria of the certificate, and reporting system.

Further dissemination workshops on the INSET guideline for other provincial organizations are also planned to conduct in the future.

Credited: Strings Project






